**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**

លេខ:.................

# សេចក្តីប្រកាសជូនព័ត៌មាន

តបតាមការអញ្ជើញរបស់ក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយអនុវត្តតាមផែនការសហប្រតិបត្តិការឆ្នាំ២០១៦ រវាងក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា និង ក្រសួងការពារប្រទេស នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ស្តីពីកិច្ចសន្ទនានយោបាយការពារជាតិ កម្ពុជា-វៀតណាម។

ឯកឧត្តម នាយឧត្តមសេនីយ៍ **នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិ នឹងដឹកនាំគណៈប្រតិភូយោធាជាន់ខ្ពស់នៃកងយោធពលខេមរភូមិន្ទ អញ្ជើញទៅបំពេញទស្សនកិច្ចមិត្តភាពផ្លូវការ ដើម្បីចូលរួមកិច្ចសន្ទនាស្តីពីនយោបាយការពារជាតិ កម្ពុជា - វៀតណាមថ្នាក់អនុរដ្ឋមន្ត្រីការពារជាតិលើកទី២ ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២០ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៦ នៅទីក្រុងហាណូយនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

កិច្ចសន្ទនាទ្វេភាគី ថ្នាក់អនុរដ្ឋមន្ត្រីការពារជាតិលើកទី២នេះ គឺជាកិច្ចសន្ទនាដែលនឹងត្រូវបន្តពីរបៀបវារៈនៃកិច្ចប្រជុំលើកទី១ ដែលបានប្រព្រឹត្តទៅនៅព្រះរាជាណាចក្រកម្ពុជា កាលពីខែតុលាឆ្នាំ២០១៥ កន្លងមក ហើយដែលនឹងពិភាក្សាបើកទូលាយអំពីទស្សនសភាពការណ៍ជាតិ-អន្តរជាតិ ពាក់ព័ន្ធនយោបាយការពារជាតិ ក្នុងស្មារតីនៃការលើកកម្ពស់ កិច្ចសហប្រតិបត្តិការ លើវិស័យនយោបាយការពារជាតិ នៃប្រទេសទាំងពីរ កម្ពុជា - វៀតណាម ក៏ដូចជាគោលដៅ នៃការពង្រឹង ពង្រីក នូវទំនាក់ទំនងមិត្តភាពសហប្រតិបត្តិការលើគ្រប់វិស័យ ដែលបានចែងនៅក្នុងពិធីសារ ស្តីពីកិច្ចសហប្រតិបត្តិការ រវាងក្រសួងការពារជាតិ នៃប្រទេសទាំងពីរ កម្ពុជា - វៀតណាម ជាពិសេសការលើកកម្ពស់ដល់ការបណ្តុះបណ្តាលធនធានមនុស្សក្នុងកងយោធពលខេមរភូមិន្ទ។

កិច្ចសន្ទនាទ្វេភាគីស្តីពីនយោបាយការពារជាតិ ថ្នាក់អនុរដ្ឋមន្ត្រីលើកទី២នេះ នឹងត្រូវបានផ្លាស់ប្តូរនូវបទពិសោធន៍ដើម្បីផលប្រយោជន៍ទៅវិញទៅមក លើវិស័យនយោបាយការពារជាតិ នៃប្រទេសទាំងពីរ ព្រមទាំងសំណូមពរ និងទិសដៅនៃកិច្ចសហប្រតិបត្តិការដែលត្រូវបន្តអនុវត្តនាពេលខាងមុខ ឆ្លើយតបទៅនឹងពិធីសារនិងផែនការសហប្រតិបត្តិការរវាងក្រសួងការពារជាតិ នៃប្រទេសទាំងពីរដែលបានដាក់ចេញ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី...១៨...ខែ...តុលា...ឆ្នាំ២០១៦